# ការសំភាសន៍របស់អ្នកមីងត្រឿង ម៉ឹងឡាយ

កៈ អ្នកដែលសំភាសន៍ញ៉ែម សុគន្ធា　　　ខៈ អ្នកដែលត្រូវគេសំភាសន៍ត្រឿង ម៉ឹងឡាយ

## <u>ការសង្ខេបរបស់អ្នកមីងត្រឿង ម៉ឹងឡាយ</u>

អ្នកមីងត្រឿង ម៉ឹងឡាយ
គាត់កើតនៅក្នុងត្រកូលអ្នករកស៊ីហើយឪពុកម្តាយនឹងជីដូនជីតាគឺជាជនជាតិចិនតែមករស់នៅក្នុងស្រុកខ្មែរតាំងពីយូរយារមកហើយ ។គាត់នឹងគ្រួសារគឺរកស៊ីលក់គុយទាវ
ហើយជីវិតអ្នកមីងនៅក្នុងនេះគាត់បានរៀបរាប់ពីពេលវេលាដែលគាត់បានរស់នៅជាមួយបងស្រីជួយរកស៊ីអោយបងប្អូន ហើយគាត់គ្មានអ្វីសោះ
អាយុក៏កាន់តែច្រើនហើយពុំទាន់មានស្វាមី ហើយគាត់ក៏បានចាកចេញពីបងស្រី
ហើយក៏មានការឈ្លោះគ្នា តែគាត់នៅតែសំរេចចិត្តចេញ
លុះដល់ប៉ុន្មានឆ្នាំក្រោយគាត់ក៏បានរៀបការមានស្វាមី
ដោយគាត់ចង់ឃើញពីជីវិតគាត់អោយបានរីកចំរើន។

កៈ
ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណដល់អ្នកមីងដែលអោយញ៉ុមសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងនាងខ្ញុំឈ្មោះញ៉ែម សុគន្ធា ជាអ្នកសំភាសន៍អ្នកមីងនៅក្នុងថ្ងៃនេះ
ហើយទីតាំងដែលយើសំភាសន៍គឺនៅភូមិថ្មី ឃុំតាខ្មៅ ក្រុងតាខ្មៅ
ខេត្តកណ្តាល។ហើយថ្ងៃដែលយើងសំភាសន៍គឺនៅក្នុងថ្ងៃទី២៦ ខែវិច្ឆិកា
ឆ្នាំ២០១៧។ហើយអ៊ីចឹងនាងខ្ញុំសូមចាប់ផ្តើមធ្វើការសំភាសន៍អំពីជីវប្រវត្តិរបស់អ្នកមីងតែម្តង
អ៊ីចឹងអ្នកមីងតើសំរាប់អ្នកមីងឈ្មោះពេញឈ្មោះអីគេដែរ?

ខៈ ត្រឿង ម៉ឹងឡាយ។

កៈ ចាំ អ្នកមីងមានឈ្មោះហៅខាងក្រៅអីអត់?

ខៈ ហៅក្រៅបានគេអោយគេហៅគឹមឡាយ។

កៈ គីមឡាយ !!ចាំអ៊ីចឹងនៅពីក្មេងមកមានធ្លាប់អ្នកណាគេហៅអីផ្សេងពីហ្នឹងទៀតទេ?

ខៈ អត់ទេឈ្មោះមានតែ២ហ្នឹង។

កៈ ចាំអ៊ីចឹងបើសិនជានៅផ្ទះគេហៅគីមឡាយអ៊ីចឹងទៅ?

ខៈ ខ្លះហៅគីមឡាយ ខ្លះហៅម៉ឹងឡាយ។

កៈ ចាំ!!តែឈ្មោះពិតឈ្មោះម៉ឹងឡាយ។

ខៈ ចាំ!!

កៈ តើសព្វថ្ងៃនេះអ្នកមីងមានអាយុប៉ុន្មានហើយ។

ខៈ ៤៥ឆ្នាំ។

កៈ អ៊ីចឹងសំរាប់ថ្ងៃខែឆ្នាំកំនើតអ្នកមីងកើតនៅក្នុងថ្ងៃទីខែឆ្នាំណាដែរ?

ខៈ ថ្ងៃទី១០ ខែ០៦ ឆ្នាំ១៩៧៣។

កៈ កើតនៅក្នុងរបបលន់ នល់!!ចាំអ៊ីចឹងឆ្នាំខ្មែរអ្នកមីងកើតឆ្នាំសត្វអីគេដែរ?

ខៈ ខ្លា។

កៈ សត្វខ្លាម៉ងហ៎?

ខៈ ចាំ ខ្លា!!

កៈ ចាំ!!អ៊ីចឹងអ្នកមីងសំរាប់ទីកន្លែងកំនើតអ្នកកើតនៅក្នុងភូមិឃុំខេត្តណាដែរ?

ខៈ ញ៉ុមកើតនៅភូមិកែង ឃុំជ្រោយបន្ទាយ ស្រុកព្រៃប្រសព្វ ខេត្តក្រចេះ។

កៈ អ្នកខេត្តក្រចេះ ។អ៊ីចឹងអ្នកមីងសំរាប់ចូលដល់ក្រុមគ្រួសារអ្នកមីងវិញម្តង
តើអ្នកមីងមានបងប្អូនប្រុសស្រីចំនួនប៉ុន្មាននាក់ដែរ?

ខៈ បងប្អូនប្រុសស្រី៩នាក់ ។ស្រី៧ ប្រុស២។

កៈ អ៊ីចឹងអ្នកមីងជាកូនទីប៉ុន្មានដែរ?

ខៈ ញ៉ុមកូនទី៧ ជិតបន្ទាប់ពៅ។

កៈ ចាំ
អ៊ីចឹងអ្នកមីងអាចប្រាប់ឈ្មោះបងប្អូនរបស់អ្នកមីងហាំតាំងពីបងគេរហូតដល់ពៅគេតើគាត់
ឈ្មោះអ្វីខ្លះទៅមីង?

ខៈ  បងស្រីធំឈ្មោះ ត្រឿង ខេងមាំង បន្ទាប់មកបងប្រុសឈ្មោះ ត្រឿង ហៀង
បន្ទាប់បងទៀតបងស្រីឈ្មោះ ត្រឿង សុខឡាយ បងស្រីមួយទៀតត្រឿង ចាឡាយ
ហើយទៅបងប្រុស បងប្រុសត្រឿង ឈង បងស្រីមួយទៀតឈ្មោះ ត្រឿង សុខមុយ ហើយក៏ខ្ញុំ
ហើយប្អូនស្រីខ្ញុំត្រឿង អៀងឡាយ ។កៈ ចាំ!ខៈ មួយទៀតពៅគេ ត្រឿង អៀងឡេង។

កៈ ពេញអស់ម៉ងអ្នកមីងចាំទាំងអស់ ។អ៊ីចឹងអើរអ្នកមីងកាត់ខ្សែចិនមែនទេ?

ខៈ ចិន។

កៈ ចិនម៉ង ព្រោះឈ្មោះ។

កៈ ចិនទាំងអស់។

កៈ
អូខេអ៊ីចឹងអ្នកមីងនៅចងចាំសាច់រឿងអីគេខ្លះជាមួយបងប្អូនអ្នកចាំថាធ្លាប់រស់នៅជាមួយគ្នា
ដោយរបៀបណា
ការញុំាបាយការលេងសើចឬក៏ការធ្វើការអ្វីមួយឬក៏ការជួយឪពុកម្ដាយអីអ៊ីចឹងហាំតើអ្នកមីងបា
នឆ្លងកាត់ប្រវត្តិអីគេខ្លះ ជាមួយបងប្អូនរបស់អ្នកមីងអាចរៀបរាប់អោយ
បានក្បោះក្បាយអ៊ីចឹងហាំ?

ខៈ ហ្វាំប្រវត្តិហាត់នឿយជាមួយឪពុកម្ដាយធ្វើគុយទាវ
ការហូបជុំគ្នាមានការរវល់ច្រើនសូម្បីតែទៅរៀនក៏ទៅមិនចង់ទាន់ដែរ រវល់លក់ដូរ
ខ្ញុំក្រោកពីយប់ឡើង ជួយហាន់គុយទាវ ជួយដឹកគុយទាវដាក់មួយហើយបានទៅរៀន
ហ្នឹងហើយហើយរៀនញ៉ុមប្រលងឌីផ្លូម៨៩(១៩៨៩)តែដល់មុខរបររកស៊ីយើងម្នាក់ឯងអត់ចេះរ

ក លក់ដូរមុខរបរលក់ដូរមួយដែរពីប្អូនស្រីញុំមការមុនញុំមជាមួយម៉ាក់គាត់ឈប់ទៅគាត់អោយញុំមលក់ តែខ្ញុំលក់ឡើងអស់ឥវ៉ាន់មួយតួប។

ក៖ ម៉េចអីចឹងវិញ?

ខ៖ លក់អត់បានដើមមកវិញទេ ញុំមអត់ចេះលក់ដូរបានលុយមុខរបរបរាជ័យ។

ក៖ ចាំលក់គុយទាវហ្នឹង?

ខ៖ អត់ទេឈប់ពីលក់គុយទាវលក់ឥវ៉ានចាប់ហ្វយវិញ។

ក៖ ហ្នូំ!!

ខ៖ ញុំមផ្សេងពីម្តាយញុំមប្អូនញុំមញុំមលក់អត់បានលុយទេ អស់ អស់ដើមរលីង ត្រូវគេចោតប្រកាន់ថា
យកលុយទៅណាហ្នឹង??ទៅអោយប្រុសឬក៏អោយអីអស់រលីងអត់មានដើមទុន។ ក៖ ចាំ!!

ខ៖ ហើយក្រោយមកញុំមក៏បានឈប់លក់ហើយមកនៅជាមួយបងស្រីជួយការងារគាត់ អើរគាត់លក់ដាច់ណាស់ គាត់ថតកាសែតម៉ាញ៉េ
យើងនៅផ្ទះយើងព្រលឹមឡើងយើងហូបដល់ព្រលឹមឡើងយើងជួយគាត់ព្រលឹមឡើងអត់បានហូបរហូតដល់ម៉ោង១១បានបានហូប ការងារគាត់លក់ដាច់ណាស់
ពេលយប់ម៉ោង១២បានបាន ចូលដេកគឺជួយគាត់អ៊ុតកាសែតម៉ាញ៉េ នៅ៥ ៦ឆ្នាំ
២០០៦បានញុំមឈប់ ឈប់នៅជាមួយបងស្រីហើយ។

ក៖ ចាំ!!

ខ៖ ប៉ុន្តែពេលឈប់ហ្នឹងគឺឈ្លោះគ្នាជាមួយបងស្រីទៀត
ព្រោះអីញុំមប្រាប់ម៉ែញុំមថាញុំមឈប់នៅជាមួយបងស្រីហើយខ្ញុំនឹងទៅនៅជាមួយប្អូនស្រីដល់តែញុំមប្រាប់គាត់ថាញុំមចេញ គាត់តេសួរថាញុំមទៅដល់ក្រចេះនៅ អ្នកក្រ ចេះអត់ដឹង អត់ដឹងគាត់ដឹងថាញុំមខូចជាមួយគាត់ គាត់នឹងតាមរក តាមរកញុំមញុំមទៅនៅផ្ទះប្អូនស្រីពៅគាត់ទៅជេរទាំង២នាក់បងប្អូន បន្ទាប់ពីជេរ២នាក់បងប្អូនញុំមក៏អត់នៅភ្នំពេញទេញុំមក៏ទៅក្រចេះ។

កៈ ចាំ!!

ខៈ ទៅក្រចេះវិញទៅ ទៅបង្កើតមុខរបរលក់នំពុម្ព បន្ទាប់ពីលក់នំពុម្ព
បានញ៉ុមដុតនំពងទាលក់ រហូតទាល់តែឥឡូវហ្នឹងដុតនំពងទាលក់។

កៈ ចាំ!!ចុះអ្នកមីងមានការចងចាំអីដែលល្អជាមួយបងប្អូនពីមុនៗមកទេ
ដែលក្រៅពីការឈ្លោះគ្នាឬក៏ខ្វែងគំនិតគ្នាអីអឺចឹងហាំ?

ខៈ ជាមួយគ្នាអត់មានអនុស្សាវរីយ៍អីល្អទេមានតែធម្មតានៅជាមួយគ្នាលក់ដូរជួយគ្នា
តែប៉ុណ្ណឹង ។

កៈ អត់មានអីដែលចងចាំបំផុតជាមួយបងប្អូនឬក៏ជាមួយនឹងបងប្អូនទីប៉ុន្មានៗ
អឺចឹងទៅណាស់??

ខៈ មានអីល្អ ធម្មតាទាំងអស់អត់មានអីពិសេសសោះ។

កៈ គ្រាន់តែរស់នៅជាមួយគ្នាសាមញ្ញធម្មតាអីអឺចឹងទៅ?

ខៈ ចាំ!!អត់មានអ្វីអនុស្សាវរីយ៍អីដែលមិនអាចបំភ្លេចបានសប្បាយបំផុតអីអត់
ឈ្លោះគ្នាមិនចេះចប់ ។

កៈ ហ្ហ៎!!

ខៈ វាមានឈ្លោះគ្នាច្រើនបងប្អូនច្រើន។

កៈ ចាំ!!ដោយសារការរកស៊ីអឺចឹង?

ខៈ ហ្នឹងហើយរវល់លក់ដូរអឺចឹងហាំ!!

កៈ ហើយអឺចឹងពេលបងចេញពីគាត់ពេលលក់កាសែតម៉ាញ៉េ ធ្វើកាសែតហោំ?

ខៈ គាត់ធ្វើកាសែតម៉ាញ៉េពេលយើងចេញគាត់តាមជេរយើង បើយើង!!

កៈ អត់ជួយគាត់មែន?

ខៈ បើយើង យើងឈប់ជួយគាត់ ។

កៈ ហើយជួយគាត់ហ្នឹងគាត់មានបានផ្តល់ប្រាក់កាសអីគួរសមឬក៏អីដែរទេ?

ខៈ គាត់អើរបានទិញ គាត់ទិញចិញ្ចៀនពេជ្រអោយមួយវង់ គាត់ថាហ្នឹងការលើកទឹកចិត្តកុំអោយញ៉ុមអាក់អន់ចិត្តនៅពេលដែលនៅជាមួយគាត់ដោយគ្មានអ្វីសោះហ្នំ ការពិតរឿងហ្នឹងគាត់នៅតែមានអាក់អន់ចិត្តជាមួយខ្ញុំ ខ្ញុំសុំគាត់ថាញ៉ុមថារកមុខរបរថ្មីមួយទៅណាស់ញ៉ុមលក់កាសែតដូចគ្នាទៅជួលកន្លែងមួយធុងបាសអីមួយអ៊ីចឹងទៅណាស់ ជួលកន្លែងគេលក់អារបស់អស់ហ្នឹងសំរាប់ជីវភាពរបស់ញ៉ុមតែគាត់ថាជួយគាត់អោយមានសិនបងថ្លៃហា៎ !!បើស្រីញ៉ុមអត់និយាយទេញ៉ុមនិយាយជាមួយបងថ្លៃ គាត់ថាជួយគាត់អោយមានសិនប៉ុន្តែចិត្តមនុស្សមិនគ្រប់ គ្រាន់គាត់មានផ្ទះនៅអូរឬស្សី គាត់លក់ដូរបានទិញផ្ទះនៅអូរឬស្សីគាត់នឹងទៅទិញផ្ទះនៅសុវណ្ណាមួយទៀតគាត់ចាំមានរហូតយើងនៅចាំជួយគាត់រហូតអត់ន័យអាយុកាន់តែចាស់គ្មានប្តីគ្នានអីនៅជាមួយគេមិនថាគេមិនថាបងយើងបង្កើតវាអត់ស្រួល ។

កៈ ចា៎!!

ខៈ អ៊ីចឹងញ៉ុមគិតឃើញ ថាញ៉ុមត្រូវតែចេញទៅណាស់។

កៈ
មួយហ្នឹងមិនដែលចាំតែជួយគាត់ហើយគាត់អត់គិតគួរពីយើងផងហ្នឹងគាត់អោយតែគ្រាន់តែទិញចិញ្ចៀនអោយមួយវង់។

កៈ ទិញចិញ្ចៀនអោយមួយវង់
ជាអនុស្សាវរីយ៍ហ្នឹងហើយសំលៀកបំពាក់ហ្នឹងធម្មតាហ្នឹងអោយសល់អីទៀតអត់មានទេ ។

កៈ តែមានលុយជាប្រចាំគាត់បានផ្តល់អោយដែរ?

ខៈ
លុយជាប្រចាំហ្នឹងហាលុយហូបចុករាល់ថ្ងៃគាត់អោយញ៉ុមទិញម្ហូបញ៉ុមទិញទៅញ៉ុមសល់ញ៉ុមចាយទៅអាហ្នឹងវាអ៊ីចឹង ។

កៈ អ៊ីចឹងអត់កើតទេ អាយុកាន់តែទៅមុខចាំតែជួយតែគេ!!

ខ៖ ចាំ!!អាយុច្រើន។

ក៖ ពិតតែថាបងប្អូនខ្លួនឯងតែយើងក៏ត្រូវដោះស្រាយសំរាប់ជីវិតខ្លួនយើងដែរ!!

ខ៖ ហ្នឹងហើយ។

ក៖ យើងត្រូវតែមានគោលដៅសំរាប់ជីវិតខ្លួនឯងដែរហ្នឹង។

ខ៖ ហ្នឹងហើយ។

ក៖ ចាំ!!

ខ៖
ត្រូវត្រលប់ទៅវិញ២០០៧នៅតែលតោលក្រចេះលក់ដូរនំលក់អីដើរលេងអីចឹងទៅរហូតដល់អើរ!!អើរ២០០៧ហ្នឹងហើយម្តាយក្មេកញ៉ុមនឹងគាត់តបានទៅក្រចេះ គាត់ទៅឃើញខ្ញុំហើយគាត់តបានប្រាប់អីម្នាក់ថាគាត់ពេញចិត្តខ្ញុំហើយកាលណាខ្ញុំមកលេងភ្នំពេញអោយមកលេងផ្ទះគាត់នឹងអោយកូនគាត់មើលអីចឹងហាំ!!

ក៖ ហ៊ើៗ!!

ខ៖ បានស្វ័យយល់ពីគ្នាប៉ុន្តែ
ពេលញ៉ុមមកញ៉ុមបានប្រាប់បងស្រីញ៉ុមថាយាយនឹងគាត់ចង់ឃើញខ្ញុំហើយនឹងកូនគាត់អីចឹងហាំ !!បងស្រីថាកុំឃ្លានប្តីពេក!!

ក៖ បងស្រីដែលនៅជាមួយ?

ខ៖
ហ្នឹងហ្នឹងៗៗៗគាត់ថាបើគេចង់បានយើងគេទៅមើលយើងហើយកុំបាច់មកសិក្សាពីគ្នាអីវ៉ាន់អីចឹងហាំ!! ៥ឆ្នាំក្រោយ២០១២ ២០០៧ ដល់២០១១គាត់យាយគាត់ទៅរកខ្ញុំម្តងទៀត គាត់សួរញ៉ុមថាមានប្តីអីចឹងនៅអីចឹងហាំ!!ទៅសួរអីហ្នឹងបានអីហ្នឹងគាត់ទំនាក់ទំនងមកខ្ញុំគាត់ប្រាប់ថាគាត់ថាអត់ទាន់មានប្តីបានម៉ែក្មេកញ៉ុមទៅ។

ក៖ ហ្ហ៎!!

ខ៖ ចុងឆ្នាំថ្ងៃ៣១ហាំ!!២០១១ម្តាយ
ក្មេកញុំមទៅជួបគ្នានិយាយគ្នាមួយថ្ងៃស្អែកឡើងដឹងបានខលហៅប្តីញុំមទៅក្រចេះអោយបងប្រុសបងថ្លៃញុំមអីឃើញមុខគេទាំងអស់នឹងព្រមព្រៀងគ្នា!!

ក៖ រៀបការទៅ?

ខ៖ ការតែ១៤ថ្ងៃទេណាស់ !!ឃើញថ្ងៃ០១
ថ្ងៃ១៤ញុំមនឹងរៀបការគឺញុំមអួយវង្វេងវង្វន់អស់ហើយ ១៤ថ្ងៃណារត់ធៀប ណារៀបផ្ទះណារៀបចំខ្លួនប្រាណ។

ក៖ ហើយចុះវេលាអីក៏ម្លេះៗ។

ខ៖ បងថ្លៃញុំមគាត់ចេះវេលាស្រាប់គាត់និយាយអីលឿនអ៊ីចឹងម៉ង។

ក៖ ចាំគាត់ថាវេលាហ្នឹងត្រូវម៉ងហេ?

ខ៖ ហ្នឹងហើយ។

ក៖ ដល់ពេលលឿនអ៊ីចឹងពេកយ៉ាប់ដែរ។

ខ៖ ហើយជីវិតប្តីខ្ញុំគាត់មិនមែនកំលោះគាត់ពោះម៉ាយ កូនមួយអាយុ៤
៥ឆ្នាំហ្នំ!!ពេលញុំមហុចធៀបបណ្តើរបងប្រុសបងប្រាប់ថាហ៊ីអាឡាយតិចគេលែងគ្នាមិនទាន់ដាច់ទៅ!!ការពិតគាត់កិច្ចការអស់ហ្នឹងគាត់និយាយជាមួយម្តាយក្មេកញុំមសព្វគ្រប់គាត់មិនដែលស្តាប់អីទេណាស់ ញុំមណាអ្នកទៅស្តាប់ ពេលហ្នឹងមិនយំហើយហោ
ហុចធៀបបណ្តើរនិយាយថាគេលែងគ្នាមិនដាច់ យំ យំបណ្តើរហុចធៀបបណ្តើរ
ការបណ្តើរក៏យំបណ្តើរដែរ រហូតដល់តែនៅជាមួយម្តាយក្មេកគឺនៅបណ្តើរយំបណ្តើរ។

ក៖ ពិបាក?

ខ៖ វាលំបាក។

ក៖
ហ៊ីជីវិតដូចរៀងយ៉ាប់ដែរហ្នឹងអ្នកមីង!!ពេលលំបាកជាមួយម្តាយក្មេក៣ខែពិបាកច្រើនបើនិយាយទៅដូចខ្ញុំហែកកេរ្តិ៍ខាងគាត់ បើសិនជាខ្ញុំនិយាយអោយអស់ដូចហែកកេរ្តិ៍ខាងគាត់

ខ្ញុំជាស្រីសម័យថ្មីញ៉ុមមិនចូលចិត្តការបំរើបើសិនជាខ្ញុំ
យល់ពីរបៀបបំរើដូចឥឡូវយើងដឹងថាសុខចិត្តបំរើយើងធ្វើតាមព្រះអង្គសង្គ្រោះប្រហែលមិន
មានរឿងច្រើនអីអឹចឹងហាំ ញ៉ុមអត់ព្រមបំរើ ប្តីញ៉ុមក៏គាត់អត់ព្រមបំរើ
ដល់អឹចឹងត្រូវម្តាយក្មេកជេ ជេទាំងប្តីជេរទាំងយើង អត់ព្រមបំរើ។

កៈ អត់ធ្វើការនៅក្នុងផ្ទះទាំងអស់?

ខៈ បំរើបងថ្លៃហ្នឹងហាំ!!

កៈ ហ្នំ!!

ខៈ បំរើសាច់ថ្លៃហ្នឹងហាំ!!

កៈ ហើយទៅអិចឹងវិញតែគេរៀបការគឺប្តីប្រពន្ធគេហើយ។

ខៈ ចាំ!!យើងខ្ញុំត្រូវការសិទ្ធសេរីភាពដើម្បីប្តីប្រពន្ធរបស់ខ្ញុំ ខ្ញុំមិនត្រូវការបំរើសាច់ថ្លៃទេ
បានញ៉ុមអត់បំរើអត់បំរើត្រូវគាត់ជេរ តែគាត់ជេរយើងខឹងហើយ
គាត់ដៀលយើងស្រីអីមិនចេះទុកដាក់កិច្ចការប៉ុណ្ណឹងមិនចេះទុកដាក់ ខ្ញុំថាខ្ញុំចេះទុកដាក់
កូនគាត់ទេដែលមិនចេះទុកដាក់ ។

កៈ ចាំ!!

ខៈ មាសមួយដំឡឹងពីរដំឡឹងញ៉ុមក៏ចេះទុកដាក់
របស់អើរអាដែលស្រមែមស្រមាមញ៉ុមមិនចេះទុកដាក់មិនចេះរៀបអីទេ
គាត់និយាយអោយយើងអឹចឹងហើយញាតិជិតខាងគេប្រាប់យាយថាខ្ញុំដៀលគេហើយមានរឿង
រហូតទាល់តែឥឡូវថាយើងដៀលគេមិនចេះ
យើងចេះតែដុះនំបារាំងគេចេះដល់ពេទ្យអីអឹចឹងហាំ!!ថាមិនត្រូវដៀលគេអឹចឹងទេណាស់!!ប៉ុន្តែ
តាមការពិតកំហឹ
ងភ្លាមៗដែលគាត់ជេរយើងយើងថាអញ្ចឹងយើងក៏ឆ្លើយអឹចឹងមកណាស់។តែយាយគាត់អត់ឮ
ទេអ្នកជិតខាងគាត់ឮគាត់ទៅប្រាប់។

កៈ អឹចឹងទៀតមានអាអ្នកជិតខាងអុជអាលទៀត!!

ខ៖ ហ្នឹងហើយរៀនអភ័យទោសចំពោះយាយម្នាក់ហ្នឹងហិ។

ក៖ ចាំ!!

ខ៖ គាត់ចូលចិត្តនិយាយអីពីខ្ញុំប្រាប់ម្ដាយក្មេកប៉ុន្តែឥឡូវខ្ញុំបំភ្លេច។

ក៖ ចាំ!!

ខ៖ ញ៉ុមនៅតែធ្វើល្អជាមួយគាត់។

ក៖ អោយគាត់ឃើញមីង!!

ខ៖ ធ្វើល្អចំពោះគាត់។

ក៖
ថាទោះធ្វើអាក្រក់ដាក់ញ៉ុមម៉េចក៏ដោយតែអ្វីទាំងអស់ញ៉ុមនៅតែធ្វើល្អដាក់អ្នកអីចឹងមនុស្សហ្នឹងនឹងដឹងម៉ងអ្នកមីង កុំខ្វល់ ចាំអីចឹងសំរាប់សំនួរបន្តទៀតហាំពីបងប្អូនហ្នឹងបន្ថែមតិចទៀត អីចឹងពួកគាត់ទាំងអស់គ្នាដែលគាត់ជាបងប្អូនអ្នកមីងគាត់រស់នៅទាំងអស់ឬក៏មានខ្លះអនិច្ចាកម្មខ្លះទៅហើយ?

ខ៖ បងប្អូនបង្កើតស្លាប់២នាក់ហ្នឹងកាលតាំងពីក្មេងៗម្លេះបងស្រីធំហាំ!!

ក៖ ចាំ!!

ខ៖ ស្លាប់២នាក់ហើយកាលពី ក្មេងៗ។

ក៖ គាត់ស្លាប់មូលហេតុអី?

ខ៖ គាត់កើតកញ្ជ្រឹលកើតអីហាំ!!ហ្នឹងធំហើយបើនៅ៦០ជាងហើយ។

ក៖ ចាំ!!

ខ៖ ដែលបងស្រីធំ៩នាក់និយាយទាំងអស់១១ស្លាប់២នៅសល់៩ហ្នាំ!!

ក៖ ហ្នាំចឹងម៉េចរៀបរាប់បានតែ៩ទេអីចឹង?

ខ៖ បានតែ៩ ហ្នឹងអាហ្នឹងអ្នកដែលនៅរស់ទេ។

ក៖ ចុះ២នាក់ដែលស្លាប់ហ្នឹងឈ្មោះអីគេ?

ខ៖ ២នាក់ដែលស្លាប់គ្មានដឹងឈ្មោះទេ។

ក៖ អត់ស្គាល់ម៉ង??

ខ៖ ព្រោះម៉ែប៉ាញ៉ុមប្រាប់ថាគាត់នៅតូចៗទេ ស្លាប់ទាំង២នាក់នៅតូចៗ។

ក៖ ហ៊ីគាត់អត់មានអំពើបាបទេមីងណោះ?

ខ៖ ចាំគាត់អត់មានអំពើបាបហ្នឹងហើយ។

ក៖ គាត់ទទួលបានសេចក្ដីសង្គ្រោះយកម៉ង។

ខ៖ វាឈឺមានជំងឺខ្វះការថែទាំអីចឹងទៅណាស់!!!

ក៖ ហ៊ីៗ!!

ខ៖ ហើយស្លាប់ទៅ។

ក៖ ឥឡូវមីងពួកគាត់នៅឯណាអ្នកដែលនៅរស់ហ្នឹងហាំ?

ខ៖ នៅខ្មែរទាំងអស់ឬក៏គាត់ទៅណា?

ខ៖
នៅស្រី៥នាក់នៅភ្នំពេញទាំងញ៉ុមបងស្រីគេហៅថារាប់តាមចិនបងស្រីទី២នៅពោធិ៍ចិនតុង បងស្រីខ្ញុំនៅកាណាឌីយ៉ា ប្អូនស្រីនៅស្ទឹងមានជ័យ លក់ដូរនៅអូរឬស្សី។

ក៖ ដល់ពេលប្រុសៗនៅខ្មែរហ្នឹងដែរ?

ខ៖ នៅខ្មែរហ្នឹងដែរនៅក្រចេះហ្នំ!!

ក៖ ហ្នំ!!

ខ៖ បងប្រុស២នាក់នៅក្រចេះហ្នំ ក្រចេះ ហើយបងស្រី២ប្អូនស្រីមួយ។

កៈ នៅក្រចេះ។

ខៈ នៅចែកគ្នា។

កៈ អ៊ីចឹងសំរាប់អ្នកមីង ម្តាយអ្នកមីងវិញតើម្តាយរបស់អ្នកមីងគាត់ឈ្មោះអីគេ?

ខៈ ម្តាយខ្ញុំឈ្មោះ ថៅ ងីម។

កៈ ចុះឪពុកវិញ?

ខៈ ឪពុកឈ្មោះ គ្រឿង វែង។

កៈ អ៊ីចឹងសំរាប់ម្តាយអ្នកមីងចាំថ្ងៃខែឆ្នាំកំនើតរបស់គាត់ទេ?

ខៈ ខ្ញុំដឹងថាគាត់៧០ជាង។

កៈ អ្នកមីងអាចប្រាប់ថ្ងៃខែឆ្នាំកំនើតរបស់គាត់ហាំ!!

ខៈ ម្តាយញ៉ុមឆ្នាំថោះ ៧០ហើយគាត់ស្លាប់តាំង២០១២។កៈ ចាំ!!អាយុ៧៤ឆ្នាំ។

កៈ ហ្នឹងហើយប៉ុន្តែអត់ចាំថ្ងៃកើតគាត់ទេហី?

ខៈ ញ៉ុមអត់ចាំបានសរសេរនៅក្នុងពង្សប្រវត្តិ។

កៈ អត់អីមួយហ្នឹងដោយសារបើគាត់ចង់ដឹងគាត់
កូនចៅចង់ដឹងអាយុគាត់ប៉ុន្មានគាត់អាចដកដឹងហើយដោយសារឆ្នាំ២០១២គាត់អាយុ៧៤គាត់ស្លាប់។

ខៈ គាត់ស្លាប់។

កៈ អ៊ិចឹងគិតទៅដឹងថ្ងៃឆ្នាំគាត់កើតហើយ ចាំហ្នឹងហើយ ។អ៊ីចឹងសំរាប់ឪពុកអ្នកមីងវិញ?

ខៈ ប៉ាឈ្មោះ គ្រឿង វែង។

កៈ ហើយគាត់កើតនៅថ្ងៃណាខែណាដែរមីង?

ខ៖
គាត់អើរប៉ាហើយនឹងម៉ែហ្នឹងគាត់កើតនៅស្រុកចិនដូចគ្នាហើយកង់យកមកនៅស្រុកខ្មែរតាំងពីតូចៗដូចគ្នាអ៊ីចឹងហាំ!!គាត់ឆ្នាំរក ៨០ជាងហើយនេះ!!មិនដឹងជា៨៦ ៨៥។

ក៖ គាត់នៅរស់ដល់ឥឡូវហ្នឹង?

ខ៖ ហ្នឹងហើយប៉ាញ៉ុមនៅរស់។

ក៖ អ៊ីចឹងប្រហែលជា៨៥ ៨៦។

ខ៖ ហ្នឹងហើយ។

ក៖ អ៊ីចឹងនៅរស់ដល់សព្វថ្ងៃហ្នឹង ឆ្នាំ២០១៧ គាត់នៅរស់អាយុ៨៥ ៨៦ហ្នឹងអត់ទាន់ច្បាស់ថាមួយណា!!អ៊ីចឹងពួកគាត់ទាំង២នាក់ទាំងអស់គ្នាដូចកើតនៅក្នុងប្រទេសចិនទាំងអស់ម៉ង?

ខ៖ គាត់កើតនៅប្រទេសចិន។ម្តាយបង្កើតរបស់គាត់បានស្លាប់តាំងពីរតូចដូចគ្នា ឥឡូវញ៉ុមចង់ជួយរបៀបពង្សប្រវត្តិអត់មានអ្នកណាស្គាល់សោះថាម្តាយគាត់ឈ្មោះអី ម្តាយបង្កើត ព្រោះគាត់ស្លាប់ចោលតាំងពីគាត់នៅក្មេង ដូចគ្នាខាងម៉ែញ៉ុមក៏អ៊ីចឹងខាងប៉ាញ៉ុមក៏អ៊ីចឹង ស្គាល់តែម្តាយចុងបានស្គាល់ឈ្មោះរៀបរាប់អាយុអីគេហ្នឹង។

ក៖ តែគាត់ខ្មែរម្តាយចុងហ្នឹង?

ខ៖ ម្តាយចុងចិន ខាងម៉ែញ៉ុមម្តាយចុងខ្មែរ។

ក៖ ហ្នំតាមពិតម្តាយបង្កើតឪពុកបង្កើតរបស់អ្នកមីងគឺចិនសុទ្ធម៉ង?

ខ៖ ចិនសុទ្ធ។

ក៖ មីងមានស្គាល់ថាគាត់កើតនៅខេត្តណានៃប្រទេសចិនអត់?គេអត់ប្រាប់ម៉ង?

ខ៖ គេអត់មាននិយាយទេ។

ក៖ ហើយចិនប៉ុណ្ណាណរីទៅរកនៅឯណាទៅដូនតា។

ខ៖ កោងតុង កោងចូវមិនដឹងកោងតុងមិនដឹងកោងចូវប៉ាញ៉ុមហ្នំគាត់ចេះតែនិយាយដែរ ខេត្តមួយហ្នឹង!!ក៖ ចាំ!!ខ៖ ហើយក៏គាត់ប្រាប់ថាពេលបងគាត់នៅប្រទេសចិនហ្នឹងគេសុំយកទៅចិញ្ចឹមហ្នឹងអត់មានពីណាទំនាក់ទំនង ប៉ាញ៉ុមមានប្អូនប្រុសគេសុំយកទៅចិញ្ចឹមគាត់អត់មានទំនាក់ទំនងគាត់អត់មានឈ្មោះអីអត់ដឹង។

ក៖ ហ៊ឺ!!បិទជិតឆឹងម៉ងហោ?

ខ៖ បិទអស់ហើយ។

ក៖ អ៊ីចឹងអ្នកមីងសំរាប់ម្ដាយរបស់អ្នកមីងវិញតើអ្នកមីងបានចងចាំរឿងអីគេខ្លះជាមួយនឹងគាត់ដែរ?ដូចជាអនុស្សាវរីយ៍ជាមួយម្ដាយតើគាត់ជាមនុស្សបែបណាដែរអ៊ីចឹងហាំ?

ខ៖ គាត់កាច គាត់កាចមូលហេតុដែលគាត់រវល់ការងារអីអ៊ីចឹងច្រើន !!

ក៖ ចាំ!

ខ៖ ហត់នឿយច្រើន ចំហុយគុយទាវលក់គុយទាវហត់ណាស់ ញ៉ុមបានជួយធ្វើគាត់លក់គុយទាវហ្នឹងហត់នឿយគ្រប់គ្នា។

ក៖ គុយទាវទឹកឬក៏ធ្វើសរសៃរគុយទាវ?

ខ៖ គុយទាវសរសៃរចាំ!!

ក៖ ហ្នំ!!

ខ៖ គុយទាវសរសៃរទី១ យកអង្ករ វាល់អង្ករមួយល្អីយកទៅត្រាំទឹកហើយលាងស្រក់វាឡើងយកមកលែងគ្រឿងកិនហើយយកមកចំហុយហើយហាលអោយស្ងួតយកមកលៀបខ្លាញ់ហើយរៀបវាទុក ហើយព្រលឹមឡើងម៉ោង៤ក្រោកហាន់វាចេញសរសៃតូចៗៗមកយកទៅលក់។

ក៖ អ៊ីចឹងអាទូចៗហ្នឹងគេហាន់ទេចុះ?

ខ៖ ចាំមានម៉ាស៊ីនវាធ្មេញវាចូលគ្នាអ៊ីចឹងទៅណាស់ ដល់ពេលវាវីចូលគ្នាអ៊ីចឹងវាដាច់សរសៃគុយទាវហ្នឹងចុះមកហើយ។

ក៖ ហ្ហ៎!!

ខ៖ បានចេញជាសរសៃល្អិតៗហ្នឹង។

ក៖ ហើយគេយកទៅហាលទេ?

ខ៖ ចាំ!!ខ្ញុំចំហុយហើយខ្ញុំយកទៅហាលវាស្ងួតល្មមៗយើងនឹងសារវាមកលៀបខ្លាញ់វារៀបទុកហាំកុំអោយវាចប់ ពេលព្រឹលឹមម៉ោង៤អីក្រោកឡើងថ្លឹងអាហ្នឹង១០គីឡូ២គីឡូទៅតាម៉ូយអ៊ីចឹងទៅណាស់!!ចែកម៉ូយញ៉ុមនឹងអ្នកទៅដឹកចែកទៅ ។

ក៖ ហ្ហ៎!!

ខ៖ វាហត់នឿយច្រើនអនុស្សាវរីយ៍វាមានពិបាកវាមានផ្អែមល្ហែមហាំ!!

ក៖ ចាំ!!ហត់ពេក!!

ខ៖ ហត់ពេក។

ក៖ ភាគច្រើនខ្សែចិនរកស៊ីតែខាងគុយទាវ។

ខ៖ តែខំខ្លាំងណាស់ញ៉ុមអានិតម៉ែញ៉ុមខំហាំ!!

ក៖ តែមើលទៅជីវិតគាត់បានជោគជ័យអីច្រើនអត់អ្នកមីង?

ខ៖ ជោគជ័យពេលចាស់ពេលកូនការទៅគេមានប្ដីគេមានអ៊ីចឹងគេសល់លុយគេសប្បាយគេនាំគាត់ដើរលេងដែរ ចុងក្រោយគាត់ជិតខូច នាំគាត់ទៅដើរលេងទៅនេះទៅនោះដូចខ្ញុំជូនគាត់ទៅស្រុកយួនទៅលេងផងទៅពិនិត្យជំងឺអីផ

ងទៅ ញ៉ុមទៅស្រុកយូនមានតែញ៉ុមទេព្រោះអីយើងអត់ទាន់មានប្តីហា
យើងទៅយើងអត់មានប៉ះពាល់ស្អីណា។

ក៖ ចាំ!!

ខ៖ ទៅតែ២នាក់ម៉ែទៅ។

ក៖ ដើរលេង។

ខ៖ ដើរលេងទៅ។

ក៖ ពិនិត្យជំងឺផង!!

ខ៖ ចាំ!!

ក៖ អ៊ីចឹងអ្នកមីងចំនុចកន្លែងណាដែលអ្នកមីងស្រលាញ់ម្តាយជាងគេ តើគាត់ម៉េចដែរ?

ខ៖ ស្រលាញ់
!!ដល់ពេលចុងក្រោយអានិតគាត់ដែរថាហ៊ីខ្ញុំបានទំនេរជូនគាត់ដើរទៅលេងទៅណេះទៅ
ណោះហើយគាត់តាមញ៉ុមថាទៅណាហ្នឹងគាត់ពាក្យចាស់គាត់អត់ចោលទេអាកន្ទុយ ហ្អង
!!ទៅណាហ្អងថ្ងៃហ្នឹងអោយម៉ែទៅផងណាស់ ញ៉ុមថាម៉ែទៅតាមខ្ញុំបាន
ម៉ែទៅមុជទឹកផ្លាស់ខោអាវសិនណាស់!!។

ក៖ ចាំ!!

ខ៖
ប្រហែលគាត់មនុស្សចាស់គាត់ខ្លាចទឹកគាត់អត់ចង់មុជទឹកគាត់អត់ចង់មុជទឹកអោយម៉ែមុជទឹក
សិនណាស់ផ្លាស់ខោអាវហើយចាំទៅជាមួយខ្ញុំ
ខ្ញុំនឹងនាំទៅដើរលេងផ្ទះកូននេះកូននោះទៅអ៊ីចឹងហាំ!!សប្បាយពេកជិតខ្ញុំការហាំ។

ក៖ ចាំ!

ខ៖ សប្បាយចិត្តនាំដើរលេង គាត់នឹងពេញចិត្តញ៉ុមនឹងដែរគាត់ថា ចង់ទៅដើរលេងណាំ ទៅ
ទៅណាប្រាប់គាត់ទៅ គាំតទៅដែរ សុំយើងដូចពួកម៉ាក់អ៊ីចឹងហាំ ចុងក្រោយហ្នឹងហាំ!!!

កៈ មីងនឹកម្តាយ
តែអត់អីទេដោយសារតាមរយៈដំនឹងល្អអត់បញ្ហាទេអ្នកមីងតែតិចទៀតជួបគាត់វិញហើយ
តែប៉ុន្មានឆ្នាំ១០០ឆ្នាំអីទៀតពេលក្រោយតាមផែនការរបស់ព្រះរៀបចំអោយអីចឹងទៅណាស់អ្នកមីង!!!
អូខេអីចឹងសំរាប់ឪពុកម្តងវិញគាត់ជាមនុស្សអត្តចរិកម៉េចដែរហើយដូចជាគាត់ផ្តល់សេចក្តីស្រលាញ់អោយអ្នកមីងម៉េចដែរអីចឹងហាំ?

ខៈ
ឪពុកក៏ដូចគ្នាតាំងពីញ៉ុមធំដឹងក្តីមកដឹងតែគាត់ហូបស្រាគាត់កាចគាត់ឈ្លោះគាត់ជេរម៉ែញ៉ុមអីចឹងហាំ!!គាត់ជេរទាំងកូនអីអីចឹងហាំ!!គាត់ហូបស្រា
គាត់អត់កែចរិកទេហូបស្រាហូបទាល់តែឥឡូវ ប៉ុន្តែគាត់ងងឹតភ្នែកហាំ!!
គាត់ងងឹតភ្នែកតាំងពី៩១(១៩៩១)មក៩១ ៩២(១៩៩១ ១៩៩២)គាត់ងងឹត
អារម្មណ៍មួម៉ោគាត់ងងឹតគាត់នឹងជេរអីវ៉ាន់អីចឹងហាំ!!និយាយច្រើនរអ៊ូច្រើនហាំ!!

កៈ អីចឹងជីវិតរៀងពិបាកណាស់ណោះ?

ខៈ ហ្នឹងហើយជីវិតវាមិនសូវមានផ្អែមល្ហែមទេ  វាហត់នឿយវាច្រើនពេក ។

កៈ ចាំ!!

ខៈ
ហត់នឿយច្រើនពេកហើយគាត់ចូលចិត្តហូបស្រាអីចឹងទៀតវាពិបាកនឹងផ្អែមល្ហែមណាស់!!វាគ្មានអនុស្សាវរីយ៍ល្អ។

កៈ គាត់រករឿងហ៎ពេលហូបស្រា?

ខៈ
ពួកខ្ញុំមិនយល់ដែរពីមុនអត់គាត់អត់ររករឿងញ៉ុមចងចាំថាគាត់ងងឹតភ្នែកគាត់ស្រែ្តសហាំគាត់នៅម្នាក់ឯងយូរៗគាត់ធុញគាត់ជេរដូចគាត់ដូចលឺបិសាចអីនិយាយដាក់ត្រចៀកគាត់ហ្នំហើយគាត់ជេរ គាត់ជេរធ្វើអោយយើងធុញទេ
ហើយមួយរយៈក្រោយយើងយូរៗទៅជួបគាត់ម្តងយើងសប្បាយចិត្តអត់មានរឿងអីត្រូវជេរយើងទេ !!!!

កៈ គាត់នៅជាមួយអ្នកណាគេ កូនទីប៉ុន្មាន?

ខៈ នៅជាមួយបងប្រុសតូច ចាំបងប្រុសតូច គឺអ្នកនៅជាមួយគេធុញម្តងហើយ។

កៈ អត់មានផ្ទេរអោយអ្នកណាគេនៅជាមួយប៉ាម្តងទេហេ៎?

ខៈ
គាត់នឹងអត់ប្តូរទៅនៅជាមួយអ្នកណាព្រោះអីញ៉ុមការញ៉ុមនៅជាមួយគាត់ញ៉ុមធុញប៉ុន្មានឆ្នាំ
២០០៧ញ៉ុមចេញពីបងស្រីទៅនៅ៥ឆ្នាំណាស់ធុញទ្រាន់ជាមួយគាត់
ប៉ាម៉ែញ៉ុមគាត់ខ្លាចញ៉ុមចេញ ដើរទៅណាបាត់ចោលគាត់
ទៅលក់ដូរមួយព្រឹកហ្នឹងគាត់ជេរញ៉ុមទៅណាំបាត់មួយព្រឹក ជេរចំអេសចំអាសទៀត
ហ្នឹងហើយ។

កៈ អ៎ូ!!គាត់ចង់អោយនៅផ្ទះតែថៃទាំគាត់?

ខៈ គាត់ចង់អោយតែនៅផ្ទះប្រាជ្ញជាមួយគាត់អីណាស់ ហ៊ីបាយទឹកអីហើយប្រាជ្ញហើយ
ហើយយើងមានទៅចង់ប្រាជ្ញអីគាត់ច្រើន យើងនឹងចង់ទៅនេះទៅនោះអ៊ីចឹងហាំ។

កៈ ចាំ!!គាត់កំប្លែងណាស់អ៊ីចឹង។

ខៈ ចង់អោយយើងនៅប្រាជ្ញជាមួយគាត់មែន ចង់អោយយើង !!ពេលហ្នឹងគាត់ភ័យខ្លាចហើយ
ភ័យខ្លាចដែលថាគ្មានអ្នកណានៅផ្ទះហ្នំ!!

កៈ ចាំ!!

ខៈ ប៉ុន្តែក៏ចង់អោយយើងមានប្តីដែរគាត់ថាមានប្តីទៅកុំអោយថាថ្ងៃក្រោយវាពិបាកហាំ!!

កៈ ចាំ!!

ខៈ តែអត់ពីម៉ែប៉ាទៅទៅនៅជាមួយអ្នកណាវាមិនស្រួលទេ
យើងមានបទពិសោធន៍នៅជាមួយបងស្រីហ្នំ!!អត់ស្រួលទេ!!

កៈ វាពិបាកណាស់អ៊ីចឹង?

ខៈ ដឹងមែន អ៊ីចឹងញ៉ុមថាញ៉ុមព្រមយកប្តីតាមគាត់អីអ៊ីចឹងទៅណាស់!!

កៈ អូខេ!!អ៊ីចឹងឪពុកម្ដាយចប់ហើយចូលដល់ជីដូនជីតាវិញម្ដង សំរាប់ជីដូនជីតាខាងម្ដាយមុន ចាំថា!!អ្នកមីងអត់ទាន់ធ្លាប់ឃើញមុខពួកគាត់ឯណាមែនទេកើតមក?ដោយសារថាម៉េចស្លាប់អស់ហើយ!!ស្លាប់តាំងពីម៉ែឪនៅតូចៗមែនទេ?

ខៈ នៅជីតា ហើយនឹងម្ដាយចុង ម៉ាចុងហាំ!!

កៈ ហ្ហ៎!!

ខៈ ម៉ាចុងខ្ញុំដូចជាអត់សូវចាំច្រើនទេព្រោះអីអត់សូវជិតស្និត។

កៈ ចាំ!!

ខៈ តែកុងទេ។

កៈ កុងគាត់ឈ្មោះអីគេដែរខាងម្ដាយហាំ??

ខៈ កុងឈ្មោះ ប៊ុន ថៅ ហ្នឹងហើយគេហៅតែគាត់ថាកុងថៅកុងថៅ។

កៈ កុងថៅ?

ខៈ ហ្នឹងហើយ
អើរពេលនោះញ៉ុមនៅខាងជ្រោយបន្ទាយហើយប៉ាម៉ែញ៉ុមនឹងចង់មកនៅក្រចេះហ្នឹងហាំ!!ឡើងមកនៅក្រចេះគាត់នឹងមានផ្ទះនៅក្រចេះហើយចំហុយគុយទាវចំហុយអីលក់ហើយពួកញ៉ុមនឹងត្រៀមមកនៅតាមគាត់ទាំងអស់គ្នា
ហើយកុងថាអាគីមឡាយអាម៉ឹងឡាយអ៊ីចឹងហាំហើយប្អូនពៅញ៉ុមគាត់ដាក់ងារអោយអាអៀវផ្លែក្រូច គាត់ថាកុំទៅនៅភ្នំពេញ អើរកុំទៅនៅក្រចេះអីនៅនឹងជាមួយកង់ហើយ
ញ៉ុមថាខ្ញុំអត់នៅទេ ញ៉ុមនៅតាមប៉ាម៉ែញ៉ុមហើយ អាហ្នឹងស្គាល់កុងពេលចាស់ហើយណាស់។

កៈ ចាំ!!

ខៈ ពេលហ្នឹងញ៉ុមចេញពីនោះបានតែ២ ៣ឆ្នាំគាត់នឹងខូចហើយ ។

កៈ ហ៊ឺៗ!!!

ខៈ ៨០ជាងហើយ ។

កៈ ចាំអាយុ៨០ប៉ុន្មានគាត់ស្លាប់?

ខៈ គាត់មិនដឹងជាអាយុ៨០ប៉ុន្មានទេស្លាប់ ក្នុងឆ្នាំ១៩៨៦។

កៈ ហ្នំអ៊ីចឹងអ្នកមីងទឹមតែបាន១៣ឆ្នាំហ្នឹង?

ខៈ ចាំហ្នឹងហើយតាំងពីញ៉ុមនៅក្មេងគាត់ស្លាប់។

កៈ ហ្នឹងហើយចាំ។

ខៈ កាលញ៉ុមនៅរៀន។

កៈ អ៊ីចឹងគ្រាន់តែចងប៉ុណ្ណឹងពីពួកគាត់ តែកន្លែងកើតស្រុកកំណើតនៅស្រុកចិនណោះ?

ខៈ ស្រុកចិនណោះ។

កៈ ខេត្តដែលអ្នកមីងបានប្រាប់ហ្នឹង!!ចុះសំរាប់ខាងឪពុករបស់អ្នកមីងវិញម្តង ទា អាទាហៅ
មីងហៅទា?

ខៈ ហៅប៉ា។

កៈ ហៅប៉ាអត់ហៅអាទាទេហេ៎?

ខៈ ហ្នឹងហើយកុងខាងប៉ាញ៉ុមអត់ដែលបានស្គាល់អីបន្តិចទេ
គាត់ស្លាប់តាំងពី៨៤(១៩៨៤)មក។

កៈ គាត់ស្គាល់ ស្គាល់ថាគាត់ឈ្មោះអីអត់?

ខៈ ចេះតែសួរប៉ាថាកុងឈ្មោះអីទេនេះគាត់ប្រាប់!!

កៈ ម៉េចទៅ?

ខៈ ឈ្មោះទាវ៉ូច លឹម។

កៈ ចាំ!!

ខ៖ ឈ្មោះទាវ៉ូច លឹម ។ឈ្មោះហ្នឹង២ហ្នឹងដល់ញ៉ុមសរសេក្នុងពង្សប្រវត្តិញ៉ុមដាក់វ៉ូច លឹម ប៉ុន្តែថ្ងៃមុននេះញ៉ុមទៅជួបគាត់ម្តងទៀតគាត់ថា ហ្គួច លឹម !!ហ្គួចៗៗហ្នឹង ដូចជាលោកខែដូចជាព្រះអាទិត្យអីអ៊ីចឹង ហ្គួចហ្នឹង។

ក៖ ហ្ហ៎!!

ខ៖ ហើយម៉ាម៉ាចុងរបស់គាត់ហ្នឹងញ៉ុមធ្លាប់ជួប កាលពី៩៦(១៩៩៦) គាត់អាយុចាស់ហើយគាត់មកលេងភ្នំពេញ ហើយញ៉ុមបានដូចជាជួយបំរើគាត់ដូចជាមុជទឹកផ្លាស់សំលៀកបំពាក់អោយគាត់ ព្រោះអីគេមកពីកាណាដាមកនៅភ្នំពេញប៉ុន្មានថ្ងៃហ្នឹងគាត់ត្រលប់ទៅវិញទៅ!!គាត់ទៅស្លាប់ នៅកាណាដា ឆ្នាំ២០០៣។

ក៖ ចាំ!!អ៊ីចឹងអ្នកមីងហើយចុះសំរាប់លោកយាយវិញ លោកយាយខាង!!អត់ស្គាល់ឈ្មោះដែលហ៎?

ខ៖ ហ្នឹងហើយ លោកយាយខាងម៉ែហ្នឹង។

ក៖ ខាងឪពុកហ្នឹងហាំ?

ខ៖ ហ្នឹងហើយយាយខាងឪពុកអាម៉ាហ្នឹងឈ្មោះយាយ យាយ!!

ក៖ អាម៉ាដើមមិនមែនអាម៉ាចុងទេណាស់?

ខ៖ ហ្ហ៎!!អាម៉ាដើមអត់មានពីណាស្គាល់អីបន្តិចទេ!!យាយហ្នឹងឈ្មោះ គួច ឆេងហ៊ួយ។

ក៖ គួច ឆេងហ៊ួយ គឺអាម៉ាចុង?

ខ៖ គួច ឆេងហ៊ួយអាម៉ាចុងខាងឪពុក ដល់អាម៉ាចុងខាងម្តាយឈ្មោះ អ៊ុង សុច្ធហើយនឹងគាត់ខ្មែរសុទ្ធម៉ងមុខធំៗ មាឌធំខ្មៅមិនសូវជិតស្និតទេ របៀបប្អូនម៉ែញ៉ុមគាត់នៅជាមួយម៉ាហ្នឹងហើយផ្ទះគាត់នៅខាងលិចផ្លូវពួកគាត់មិនចូលចិត្តពួក ខ្ញុំនឹងបងស្រីញ៉ុមខ្ញុំអីដឹកគោកាត់ក្រោមផ្ទះគាត់អីអ៊ីចឹងហាំ អ៊ីចឹងហើយវាអត់សូវស្និតតាំងពីតូចហ្នឹងមក!!!មិនសូវស៊ីសង្វាក់គ្នាទេ។

កៈ ចាំហ្នឹងហើយអ៊ីចឹង។អ៊ីចឹងប្រវត្តិដូនតាអត់ចាំ
តែគ្រាន់តែថាដឹងដែរថាទាំងខាងឪពុកទាំងខាងម្ដាយបង្កើតៗគឺអ្នកមកពីស្រុកចិនទាំងអស់!!
អ៊ីចឹងសំរាប់ចូលដល់ក្រុមគ្រួសារតើអ្នកមីង ដំបូងក្រុមគ្រួសាររបស់អ្នកមីងមករស់នៅក្នុង
នៅខេត្តក្រចេះហ្នឹងយូរនៅអ្នកមីង?

ខៈ
ឪពុកម្ដាយញ៉ូមរស់នៅខេត្តក្រចេះហ្នឹងយូរហើយតាំងពីកុងហ្វូ!!កុងញ៉ុមនៅស្រុកចិនហ្នឹងមាន
ផ្ទះនៅក្រចេះហ្នឹងម៉ង ផ្ទះនៅផ្សារក្រចេះហ្នឹងម៉ង។

កៈ តែផ្ទះមកពីហ្នឹង តែដំបូងឪពុកម្ដាយរបស់អ្នកមីងមកពីស្រុកចិនដែរហោ៎?

ខៈ ហ្នឹងហើយ។

កៈ ហើយយកកូនយកអីមកមករស់នៅហ្នឹងម៉ង?

ខៈ ហ្នឹងហើយ។

កៈ ទាំងសងខាងហ្នឹង?

ខៈ ហ្នឹងហើយ។

កៈ ហ្វ៎!!

ខៈ ខាងកុងហ្នឹងមានផ្ទះនៅក្រចេះ ផ្ទះម្ដាយញ៉ុមមានផ្ទះនៅខាងត្រើយម្ខាង។

កៈ ចាំ!!

ខៈ ខាងជ្រោយបន្ទាយ ផ្ទះនៅម្ខាងម្នាក់។

កៈ អ៊ីចឹងសំរាប់នៅខេត្តក្រចេះហ្នឹងគេនៅក្នុងភូមិឃុំអីគេដែរមីង?

ខៈ បើខាងប៉ាញ៉ុមអាកុងនៅខាងឃុំក្រចេះហ្នឹងម៉ង គេហៅថាភូមិផ្សារវែង
ផ្ទះហ្នឹងនៅជិតរង្វង់មូលព្រាបហ្នឹង ។

កៈ ហ្វ៎!!

ខ៖ ផ្សារវែង ។

ក៖ អ៊ីចឹងអ្នកមីងសំរាប់សាច់ញាតិអ្នកមីងមានអ្នកណាគេធ្លាប់ទៅរស់នៅប្រទេសក្រៅអត់?

ខ៖ ប្អូនប៉ាញ៉ុមនៅប្រទេសក្រៅ
ប្អូនប្រុស២នាក់ប្អូនស្រីម្នាក់ហើយក្មួយៗដែលបងប្រុសគាត់ធំហ្នឹងគាត់ស្លាប់ហើយនៅសល់
តែប្រពន្ធទៅនៅកាណាដាជាមួយកូនហើយប្រពន្ធចុងរបស់អ៊ំហ្នឹងក៏ទៅនៅកាណាដាដូចគ្នា។

ក៖ ចាំ!!

ខ៖ ហើយអាកូវញ៉ុមនៅកាណាដាដូចគ្នា
ប្អូនជីដូនមួយកូនឪពុកមាញ៉ុមដែលនៅភ្នំពេញនេះក៏ទៅនៅកាណាដាជាមួយដែរ
ហើយជីដូនមួយ២នាក់កូនរបស់អ៊ំមីស្រីមួយប្រុសមួយក៏នៅកាណាដា។

ក៖ ចាំ!!

ខ៖ ប្អូនប៉ាមួយទៀតនៅអាមេរិច គាត់មួយគ្រួសារនៅអាមេរិច។

ក៖ នៅហ្នឹង!!!អ៊ីចឹងសំរាប់អ្នកមីងសំរាប់ចូលដល់ការសិក្សាភាសាវិញម្តង
អ្នកមីងចេះនិយាយភាសាខ្មែរ ដឹងថាចេះនិយាយហើយ
ប៉ុន្តែចេះអាននឹងសរសេរភាសាខ្មែរបានច្បាស់ទេ?

ខ៖ បានចេះអានញ៉ុមរៀនត្រឹមឪផ្លូមទេ!!អក្សរខ្មែរ។ក៖ ចាំ!!ខ៖ បើអក្សរបារាំង អង់គ្លេស
ហ្វយទៅរៀនច្រើនក៏មិនចេះ ។

ក៖ តែធ្លាប់រៀនបារាំងអង់គ្លេសអីដែរហី?

ខ៖  បារាំងក៏រៀន អង់គ្លេសក៏រៀន ភាសាថៃក៏ទៅរៀន។

ក៖ ចុះបើដោយសារមីងជាចិនអ្នកមីងចេះចិនអត់?

ខ៖ អត់ដែលចេះអក្សរចិនទេ ញ៉ុមអត់មានពេលទៅរៀន។

ក៖ ដោយសារឪពុកម្តាយគាត់មកពីចិន គាត់ដែលនិយាយភាសាចិនជាមួយទេ?

ខ៖ គាត់និយាយតើ គាត់និយាយតែខ្ញុំអត់ព្រមនិយាយទៅវិញជាមួយគាត់សោះ!!

ក៖ តែបើសិនស្តាប់មក បើសិនគាត់និយាយមកស្តាប់បានទេ?

ខ៖ ស្តាប់បានតែពាក្យគុយទាវ គុយជីវ គេហៅចិនគុយជីវ។

ក៖ ហ្នឹ!

ខ៖
ស្តាប់បានគេហៅហូបបាយធ្វើអីបន្តិចបន្តួចទេអោយនិយាយរកស៊ីជួបគ្នាប្រស្រាយអីក៏អត់ចេះស្តាប់ដែរ។

ក៖ ចាំ!!

ខ៖ ជួបគ្នាសួរអ្នកទៅណាមកពីណាហើយអ្នកធ្វើអី និយាយស្តាប់មិនបានទេ ។

ក៖ ចាំ!!

ខ៖ ញ៉ុមអត់ចេះម៉ង!!!

ក៖ ចុះធ្លាប់រៀនភាសាបារាំងអង់គ្លេសអស់ហ្នឹងបានចេះនិយាយខ្លះៗទេ?

ខ៖ ញ៉ុមចេះបានមួយឃ្លាពីរឃ្លាទេ!!បារាំងហ្នំ បើអង់គ្លេសដូចថាដំបូងញ៉ុមចេះច្រើន
ដល់តាំងពី២០០១ញ៉ុមរៀន២ ៣ឆ្នាំ ញ៉ុមរៀនពី២០០១ដល់២០០៣ញ៉ុមរៀនតែមួយម៉ោងៗទេ
រហូតដល់ ឥឡូវញ៉ុមអោយគ្រូចង់អស់ហើយ។

ក៖
ចាំអរគុណអ្នកមីងសំរាប់ការរៀបរាប់ពីប្រវត្តិពីក្រុមគ្រួសារនឹងពីអ្វីៗខ្លះដែលអ្នកមីងរៀបរាប់ពីជីវិតអីចឹងហាំ!! អីចឹងអ្វីទាំងអស់ហ្នឹងពួកយើងនឹងរក្សាទុកសំរាប់កូនចៅអ្នកមីងទៅថ្ងៃក្រោយ
ចាំអីចឹងអរគុណច្រើនអ្នកមីង។